# សំណៃនអ្នកតាព្រះថៅនៅវត្តភ្នំក្នុងរដូវចូលឆ្នាំចិន

នៅកណ្តាលរាជធានីភ្នំពេញ មានទីសក្ការៈអ្នកតាព្រះថៅ (ឬលោកតាព្រះថៅ)ដ៏ល្បីល្បាញមួយកន្លែងស្ថិតនៅក្នុងបរិវេណរមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ។ បើផ្អែកតាមរូបថតឯកសារថតក្នុងសម័យអាណាព្យាបាលបារាំងបង្ហាញថា ពីដំបូងឡើយអាស្រមអ្នកតាព្រះថៅ គឺជាអាស្រមថ្មតូចមួយ កសាងឡើងស្ថិតនៅជ្រុងខាងជើងនៃព្រះវិហារវត្តភ្នំ (រូបលេខ១-២)។ ប៉ុន្តែក្រោយមកគេដឹងប្រាកដថានៅក្នុងអំឡុងឆ្នាំ២០០៩ អាស្រមអ្នកតាព្រះថៅបានរៀបចំជួសជុល និងកែលម្អរចនាសម្ព័ន្ធទូទៅឱ្យកាន់តែធំជាងមុនដូចឃើញសព្វថ្ងៃ។ ដោយឡែកពាក់ព័ន្ធជំនឿ និងគោរពបូជាអ្នកតាព្រះថៅក្នុងសម័យបច្ចុប្បន្ននេះ គេតែងសម្គាល់ឃើញ អ្នកជាប់សែស្រឡាយចិន ឬហៅថាខ្មែរកាត់ចិន តែងចូលទៅគោរពប្រតិបត្តិជាហូរហែ ជាពិសេសនៅក្នុងរវាងមុនថ្ងៃចូលឆ្នាំចិន ដើម្បីសុំលាភសក្ការៈ មានសំណាងល្អ ជោគជ័យឆ្នាំថ្មី និងកាត់គ្រោះ(កាត់ឆុង) រំដោះចង្រៃទៅតាមជំនឿ។ ប្រហែលដោយប្រការយ៉ាងនេះ ទើបមួយរយៈកាលចុងក្រោយមហាជនខ្លះយល់ថាអ្នកតាព្រះថៅ គឺជាអ្នកតាចិន។






*រូបលេខ១-២ អាស្រមអ្នកតាព្រះថៅ មុនពេលជួសជុលកែលម្អ (ប្រភព៖ EFEO)*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិត នៅរវាងដើមទសវត្សទី៧០ គេដឹងថាមានការសិក្សាពិចារណាមួយអំពីការគោរពបូជាអ្នកតាព្រះថៅ។ នៅគ្រានោះ ក្នុងអាស្រមអ្នកតាព្រះថៅគេឃើញមានតម្កល់រូបសំណាកអ្នកតាព្រះថៅកណ្តាល រូបសំណាកកេទស្រី១នៅខាងឆ្វេង និងរូបសំណាកកេទប្រុស១នៅខាងស្តាំ ហើយអ្នកស្រាវជ្រាវយល់ថាបដិមាទាំងនេះ មានលំនាំដូចសិល្បៈលាវ (រូបលេខ២៣)។[1] បច្ចុប្បន្ន គេឃើញរូបសំណាកអ្នកតាព្រះថៅដាក់តម្កល់នៅកណ្តាល អមដោយរូបសំណាកកេទស្រីខាងឆ្វេង និងរូបសំណាកកេទប្រុសនៅខាងស្តាំដដែល។ អ្នកតាព្រះថៅ អង្គុយក្នុងឥរិយាបថបញ្ឈរជង្គង់ ដៃស្តាំដាក់លើជង្គង់ ដៃឆ្វេងកាន់មោង(?) មុខមាំ ច្រមុះធំ ចិញ្ចើមក្រាស់ ភ្នែកធំ សក់លំនាំម៉ូតស្វាបចាប (រូបលេខ២៤)។ ប៉ុន្តែក្រោយពេលជួសជុលកែលម្អរចនាសម្ព័ន្ធអាស្រមអ្នកតាព្រះថៅ គេឃើញមានរៀបចំអាសនៈ និងរូបសំណាកផ្សេងៗបន្ថែមទៀតសម្រាប់គោរពបូជាដែលមានជាអាទិ អាស្រមយាយទេព ពនទេវតា អាសនៈតាឥសី ឡជុតក្រដាសសែន ហើយជាពិសេសគឺឃើញមានរូបសំណាកតោថ្មទាំង២ និងរូបខ្លាស (ជួនកាលគេហៅអ្នកតាខ្លា អ្នកតាតោ) ដែលពុំឃើញមាននិយាយក្នុងការសិក្សាកន្លងមក។





រូបលេខ២៣ រូបសំណាកអ្នកតាព្រះថៅទសវត្សរ៍ទី៧០ រូបលេខ២៤ រូបសំណាកអ្នកតាព្រះថៅសព្វថ្ងៃ

(ប្រភព៖ *Ly Thou Kim Sea*)

[1] Ly Thou Kim Sea 1972-1973: 23

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើយោងតាមការសិក្សាអំពីជំនឿអ្នកតាព្រះចៅខាងលើ គេបានពន្យល់ខ្លីថាអ្នកតាព្រះចៅជាអមនុស្ស ដែលមាននាទីធំក្នុងការកាត់ក្តីផង ជួយព្យាបាលជំងឺផង និងជាអមនុស្សថែរក្សាទីនោះ។ មនុស្សជិតឆ្ងាយទាំងឡាយណាដែលជឿលើអ្នកតាព្រះចៅ គេតែងចូលទៅគោរពប្រតិបត្តិ អុជធូបបួងសួងដាក់សំណែនក្នុងកន្ទល់ផ្សេងៗគ្នាដូចជា អ្នកខ្លះសុំឱ្យរកស៊ីមានបាន ឱ្យជាសះស្បើយពីជំងឺផ្សេងៗ សុំឈ្នះល្បែង សុំឱ្យរកឃើញរបស់បាត់ សុំឱ្យឈ្នះក្តី និងសុំឱ្យការលក់ដូររបស់ទ្រព្យបានសម្រេចតាមបំណងជាដើម។ នៅពេលដែលការបួងសួងបន់ស្រន់ប្រាថ្នាចំពោះមុខអ្នកតាព្រះចៅបានសម្រេចហើយ គេតែងមកដាក់សំណែនសែនថ្វាយក្បាលជ្រូក មាន់ស្ងោរ ផ្កាភ្ញី នំចំណី ផ្លែឈើ ទឹកអប់ក្រណាត់ និងវត្ថុឧបកិច្ចដូចជា គ្រឿងអលង្ការ ឬយានជំនិះជា ។ល។ ប៉ុន្តែប្រសិនបើបានសម្រេចបំណងហើយ គេបំភ្លេចមិននឹកនាអ្នកតាព្រះចៅ នោះគេនឹងធ្លាក់ខ្លួនឈឺ រហូតដល់ស្លាប់ក៏មាន ឬជាពិសេសបណ្តាលឱ្យយល់សប្តិឃើញក្របី។[2] មកដល់ប្រការត្រង់នេះ គួរនឹងយើងពិចារណាបានដល់រឿងសេចក្តីស្លាប់ ដ្បិតក្នុងជំនឿដើមក្របីជាជំនិះរបស់ព្រះយមដែលជាទេពនៃសេចក្តីស្លាប់។

ដោយឡែកចំពោះគ្រឿងសំណែនបច្ចុប្បន្ន ជាពិសេសនៅក្នុងរដូវចូលឆ្នាំចិន ដែលគេតែងឃើញរៀបចំជាទូទៅសម្រាប់ថ្វាយអ្នកតាព្រះចៅរួមមាន ផ្កាភ្ញី ផ្លែឈើ (៣មុខឬ៥មុខ) នំពងទា ក្រដាសសែនកាត់ធុង និងទៀនធូប។ គ្រឿងសំណែនទាំងអស់នោះ គេរៀបជាចំណែកក្នុងថាស សម្រាប់ដាក់ថ្វាយនៅអាសនៈសំខាន់ៗ។ ប៉ុន្តែសំណែនយ៉ាងពិសេសដែលគេពុំដែលភ្លេច គឺសាច់ជ្រូកបីជាន់(ឆៅ) ពងទា(ឆៅ) និងមឹកក្រៀម (យៀវហ៊ឺ)សម្រាប់យកទៅថ្វាយក្នុងមាត់ឬដាក់លើក្បាលរូបសំណាកខ្លាសនិងតោទាំងគូ។ ចំពោះរបៀបចូលទៅគោរពបូជានោះសោត ជាធម្មតាពេលចូលដល់បរិវេណអាស្រមអ្នកតាព្រះចៅ គេត្រូវចូលអុជធូប(៣ឬ៥សសៃ)សំពះទេវតាជាមុន រួចទើបចូលទៅដាក់ដង្វាយផ្លែឈើ និងនំចំណីផ្សេងៗនៅលើតុថ្វាយអ្នកតាព្រះចៅ (រូបលេខ៥)។

[2] Ly Thou Kim Sea 1972-1973: 23-27

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៥ អ្នកមានជំនឿចូលទៅអុជធូបបួងសួងថ្វាយទេវតានៅអាស្រមអ្នកតាព្រះចៅ

បន្ទាប់ពីថ្វាយផ្លែឈើ និងនំនែកផ្សេងៗដល់អ្នកតាព្រះចៅរួចហើយ គេត្រូវចូលទៅឱ្យលោកអាចារ្យ(?)ធ្វើកិច្ចកាត់គ្រោះ។ កិច្ចនេះគេយកសាច់ជ្រូកបីជាន់ ពងទាចៅ និងយៀវហ៊ីថ្វាយរូបសំណាកអ្នកតាខ្លាស និងតោទាំងគូ។ តាមទម្លាប់ គេត្រូវរៀបចំសំណែនទាំងនោះ ព្រមទាំងក្រដាសសែន (ក្រដាសកាត់ឆុង) ដែលមានសរសេរឈ្មោះ ថ្ងៃខែឬឆ្នាំកំណើត និងអាសយដ្ឋានដាក់ក្នុងថាស ឬកន្ទោង១ (រូបលេខ៦-៩)។ រៀបចំស្រេចហើយគេអុជធូបពាសសែ បួងសួងសុំសេចក្ដីសុខ សុំធ្វើកិច្ចកាត់ឆុង ជម្រះឧបទ្រពចង្រៃឱ្យជ្រះស្រឡះក្នុងឆ្នាំថ្មី រួចហើយគេយកសាច់ជ្រូកថ្វាយមាត់ខ្លាស និងមាត់តោ ព្រមទាំងគោះបំបែកពងទា និងចុក្រោយគេថ្វាយយៀវហ៊ីដល់រូបសំណាកខ្លាស និងតោទាំងគូ។ ក្រោយមក អាចារ្យយកក្រដាសសែនកាត់ឆុងដែលមានរូបខ្លា ទៅបបោសពីក្បាលចុះមកក្រោមឱ្យបានយ៉ាងតិច១២ដង រួចបញ្ចោរ(ជូនកាលបញ្ចោរអង្ករ)គ្រោះចេញពីក្នុងខ្លួនប្រាណអ្នកមានជំនឿ ហើយយកក្រដាសនោះទៅដុត (រូបលេខ១០-១២)។ កិច្ចនៅត្រង់នេះ គេជឿថាតោនិងខ្លាទាំងនោះនឹងជួយរំដោះគ្រោះ(កាត់ឆុង) បណ្ដេញឧបទ្រពចង្រៃ ហើយនាំមកនូវសិរីសួស្ដីក្នុងឆ្នាំថ្មី។ ចុងបញ្ចប់ទើបគេចូលទៅអុជធូបតាឥសី និងយាយទេព។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៦-៩ គ្រឿងសំណែនជារណ្តាប់សំខាន់ៗកាត់គ្រោះ(កាត់ឆុង)នៅអាស្រមអ្នកតាព្រះចៅ



រូបលេខ១០-១២ អុជធូបថ្វាយសំណែនមាត់តោ និងខ្លាស ធ្វើកិច្ចកាត់គ្រោះ(កាត់ឆុង)

ជារួមមក ជំនឿនិងការសែនថ្វាយនៅអាស្រមអ្នកតាព្រះចៅវត្តភ្នំ ហាក់ដូចជាមានការវិវឌ្ឍច្រើនបើធៀបនឹងការសិក្សាកន្លងមក ជាពិសេសទិដ្ឋភាពក្នុងរដូវចូលឆ្នាំប្រពៃណីចិន។ ក្នុងបរិបទនេះ អ្នកខ្លះយល់ថាជាការទទួលឥទ្ធិពលជំនឿ និងប្រពៃណីទំនៀមទម្លាប់ចិនបន្ថែមលើជំនឿដូនតា ដែលទំនងពុំខុសពីក្នុងបុរាណកាលខ្មែរទទួលឥទ្ធិពល

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជំនឿ និងសាសនាពីឥណ្ឌា មកគោរពប្រតិបត្តិរួមគ្នាជាមួយជំនឿដើមរបស់ខ្លួនឡើយ។[3] ប៉ុន្តែយ៉ាងណាក្តី សំណៅនពិសេសៗដូចរៀបរាប់ខាងលើ គេក៏សង្កេតឃើញមានប្រើក្នុងកិច្ចមង្គលរបស់ខ្មែរខ្លះទៀត ដូចជាប្រើនៅក្នុងរៀបរណ្តាប់ជំនូនថ្ងៃមង្គលការជាដើម។

# ឯកសារយោង


*អាំង ជូលាន*

២០០០, *មនុស្ស និងដី, រៃយំ, ភ្នំពេញ*

Ly Thou Kim Sea

1972-1973, ‘Le Neak Ta Preah Chao du Vat Phnom’, *Bulletin des Études de la Faculté d’Archéologie*, No. 4-5, UBA, Phnom Penh


[3] អាំង ជូលាន ២០០០: ១-៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត